NSW GOVERNMENT | Education
Public Schools

# SCHOOL SWIMMING AND WATER SAFETY PROGRAM

## Message to Parents / Caregivers

## សេចក្តីជូនដំណឹងចំពោះមាតាបិតា / អ្នកផ្តល់ការថែទាំ

កម្មវិធីហែលទឹករបស់សាលារៀន នៃ NSW Department of Education គឺជាកម្មវិធីរៀនហែលទឹកដ៏ល្អិតល្អន់មួយ ដែលបង្កើតទំនុកចិត្តអំពីសកម្មភាពនៅក្នុងទឹក ហើយផ្តល់ឲ្យសិស្សនូវជំនាញការចាំបាច់ អំពីសុវត្ថិភាពនិងវិធីចៀសវាងការបាត់បង់ជីវិតដែលទាក់ទងនឹងសកម្មភាពនៅក្នុងទឹក។ កម្មវិធីនេះធ្វើទៅចំនួនដប់ថ្ងៃ។ មេរៀនប្រចាំថ្ងៃនីមួយៗ មានរយៈពេល 45 នាទី។

ការរៀបចំទាំងឡាយត្រូវបានធ្វើឡើងដើម្បីរួមបញ្ចូលកម្មវិធីរៀនហែលទឹកនៅក្នុងកម្មវិធីសិក្សារបស់សាលាយើង។ សិស្សដែលមិនបានលទ្ធផលទៅតាមស្តង់ដារជាទីពេញចិត្ត អំពីជំនាញការសុវត្ថិភាពនិងវិធីចៀសវាងការបាត់បង់ជីវិតដែលទាក់ទងនឹងសកម្មភាពក្នុងទឹក ហើយមិនអាចហែលទឹកជ្រៅចម្ងាយ 25 ម៉ែត្រ ដោយគ្មានជំនួយនិងមានការទុកចិត្តលើខ្លួនឯងទេនោះ មានសិទ្ធិចូលរួមក្នុងកម្មវិធីហែលទឹករបស់សាលា។ កម្មវិធីនេះផ្តោត ទៅលើអ្នកហែលទឹកអន់ខ្សោយ នៅ Years 2 and 3 ប៉ុន្តែផ្តល់ឲ្យសំរាប់អ្នកហែលទឹកអន់ខ្សោយ នៅ Years 4 to 6 ព្រមទាំងសិស្សដែលមានសេចក្តីត្រូវការចាំបាច់ ដូចជាអ្នកមកដល់ប្រទេសអូស្ត្រាលីថ្មីថ្មោង និង សិស្សដែលមានពិការភាព។

ការបង្ហាត់នឹងធ្វើទៅនៅឯ ____________________ (Name of pool)។ កម្មវិធីនេះនឹងធ្វើបន្តជា**ប្រចាំថ្ងៃ** សំរាប់រយៈពេល

**ពីរអាទិត្យ** ចាប់ពីថ្ងៃទី ____________________ (Start date) ដល់ថ្ងៃទី ____________________ (Finish date)

សិស្សនឹងធ្វើដំណើរតាម ____________________ (Means of transport) ដោយបង់ថ្លៃចំនួន $____________________ (Daily transport cost) ក្នុងមួយថ្ងៃ។

ថ្លៃចូលទៅក្នុងកន្លែងអាងទឹក គឺ $____________________ (Daily pool entry cost) កងមយថៃ ។ មនគតថៃបងាតទេ ។

ថ្លៃសរុបសំរាប់កម្មវិធី 10 ថ្ងៃ គឺ $____________________ (Total cost) ។

សិស្សនីមួយៗគួរយកទៅជាមួយនូវខោអាវងូតទឹកមួយសំរាប់ កន្សែងពោះគោមួយ អាវមួយ មួកមួយ និង ខោអាវរងានៅនឹងថ្ងៃមានអាកាសធាតុត្រជាក់។ នៅពេលធ្វើការបង្ហាត់នៅក្នុងអាងកណ្តាលវាល សិស្សគួរប្រើវិធីការពារទល់នឹងពន្លឺថ្ងៃឲ្យបានគ្រប់គ្រាន់ ឧទាហរណ៍: ប្រេងលាបការពារទល់នឹងពន្លឺថ្ងៃដែលមិនរលាយក្នុងទឹក ប្រភេទ SPF 30+ ដែលត្រូវលាបសាឡើងវិញយ៉ាងទៀងទាត់។ សិស្សគួរពាក់អាវយឺត T-shirt ឬ អាវចាស់ មួយផងដែរ (អនុញ្ញាតឲ្យពាក់ដោយកន្លែងអាងហែលទឹក)។

នៅក្នុងអម្លុងកម្មវិធីហែលទឹករបស់សាលា សិស្សនឹងទទួលការពិនិត្យវាយតម្លៃលើជំនាញការសុវត្ថិភាពក្នុងទឹកដោយពុំមានពាក់វ៉ែនតាហែលទឹក។

បើកូនលោកអ្នកមានសិទ្ធិចូលរួមក្នុងកម្មវិធីនេះ សូមបំពេញនិងចុះហត្ថលេខាលើលិខិតផ្តល់ការអនុញ្ញាត ហើយប្រគល់ទៅឲ្យគ្រូប្រចាំថ្នាក់របស់កូនលោកអ្នកវិញ។

**នាយកសាលា :** ____________________ (Name of principal) **ថ្ងៃទី:** ____________________ (Date)

KHMER